01340679

**Declassified to Public**
**12 June 2020**

លេខ៖ D326

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ការិយាល័យសហចៅក្រមស៊ើបអង្កេត
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 27 / 10 / 2016
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

សំណុំរឿងលេខ៖ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស

ចំពោះមុខ ៖ សហចៅក្រមស៊ើបអង្កេត

កាលបរិច្ឆេទ ៖ ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៦

ភាសា ៖ អង់គ្លេស & ខ្មែរ [អង់គ្លេស ភាសាដើម]

ចំណាត់ថ្នាក់ឯកសារ ៖ សម្ងាត់

# ដីកាសម្រេចរួមលើសេចក្ដីកែសម្រួលសំណើ ទី ១ សំណើទី ៨ និងសំណើទី ១១ សុំបំពេញកិច្ចស៊ើបសួររបស់ អោ អាន

**ផ្ញើជូន៖**

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្ដី អោ អាន**
មុំ លុជ្ឈ
Richard ROGERS
Göran SLUITER

**មេធាវីការពារក្ដី យឹម ទិត្យ**
សូ មូស្សេនី
Suzana TOMANOVIĆ

**សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**
ជេត វណ្ណលី
ហុង គីមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន ស៊ីវ៉ន
ទី ស្រីនណា
វ៉េន ពៅ

Linda BEHNKE
Laure DESFORGES NZEPA
Herve DIAKIESE
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Beini YE

## I. ប្រវត្តិនីតិវិធី

១.ករណីខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ("ស.ច.ស") នៅក្នុងសំណុំរឿងនេះ បានចុះបញ្ជីនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៣ និងថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥។

២. នៅថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៤ មេធាវីការពារក្តី អោ អាន ("មេធាវីការពារក្តី") បានដាក់ *សំណើលើកទី១របស់ តា អាន សុំបំពេញកិច្ចស៊ើបសួរដោយអនុលោមតាមវិធាន៥៥(១០)*[1]។

៣. នៅថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៤ អតីតសហចៅក្រមកាន់តំណែងខ្ញុំ បានបដិសេធសំណើនេះ ដោយបញ្ជាក់ថា ក្នុងនាមជាជនសង្ស័យដែលមិនទាន់បានដាក់ឱ្យស្ថិតក្រោមការពិនិត្យនៅក្នុងកិច្ចស៊ើបសួរ អោ អាន មិនមានសិទ្ធិស្នើសុំបំពេញកិច្ចស៊ើបសួរឡើយ[2]។

៤. នៅថ្ងៃទី២៧ ខែ មីនា ឆ្នាំ ២០១៥ អតីតសហចៅក្រមកាន់តំណែងខ្ញុំ បានជូនដំណឹង អោ អាន អំពីដីកាសម្រេចដាក់គាត់ឱ្យស្ថិតក្រោមការពិនិត្យពីបទប្រព្រឹត្តឧក្រិដ្ឋកម្មនៅមន្ទីរសន្តិសុខទួលបេង ទីតាំងសម្លាប់មនុស្សគោកព្រីង និងមន្ទីរសន្តិសុខវត្តអូរត្រកួន[3]។

៥. នៅថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៥ មេធាវីការពារក្តី បានដាក់*សេចក្តីកែសម្រួលសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី ១* ("សំណើទី ១")[4]។

៦. នៅថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៦ មេធាវីការពារក្តី បានដាក់ *សំណើសុំបំពេញកិច្ចស៊ើបសួរលើកទី ៨* ("សំណើទី ៨")[5]។

---

[1] សំណុំរឿង០០៤ ឯកសារ D187 *សំណើលើកទី១របស់ តា អាន សុំបំពេញកិច្ចស៊ើបសួរដោយអនុលោមតាមវិធាន ៥៥(១០)* ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៤។

[2] សំណុំរឿង០០៤ ឯកសារD190 *ដីកាសម្រេចលើសំណើរបស់ តា អាន សុំបំពេញកិច្ចស៊ើបសួរ* ថ្ងៃទី២៣ ខែមេសា ឆ្នាំ ២០១៤។

[3] សំណុំរឿង០០៤ ឯកសារD242 *កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ អោ អាន* ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥។

[4] សំណុំរឿង០០៤ ឯកសារ D187/1 *សេចក្តីកែសម្រួលសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី ១* ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៥។

[5] សំណុំរឿង០០៤ ឯកសារ D187/2 *សំណើសុំបំពេញកិច្ចស៊ើបសួរលើកទី* ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៦។

៧. នៅថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦ ខ្ញុំបានដាក់ អោ អាន ឱ្យស្ថិតក្រោមការពិនិត្យពីបទប្រព្រឹត្តឧក្រិដ្ឋកម្មថែមទៀតនៅការដ្ឋានពលកម្មដោយបង្ខំអន្លង់ជ្រៃ មន្ទីរសន្តិសុខមិត្តសុប (គរ) វត្តអង្គញជី មន្ទីរសន្តិសុខវត្តបាធាយ មន្ទីរសន្តិសុខវត្តភ្នំប្រុស វត្តតាមះ មន្ទីរសន្តិសុខចម្ការស្វាយចន្ទី មន្ទីរសន្តិសុខវត្តបារាយណ៍ជាន់ដែក និងមន្ទីរសន្តិសុខវត្តស្រងែ។ ខ្ញុំក៏បានដាក់ អោ អាន ឱ្យស្ថិតក្រោមការពិនិត្យពីបទឧក្រិដ្ឋអាពាហ៍ពិពាហ៍ដោយបង្ខំនៅស្រុកកំពង់សៀម និងស្រុកព្រៃឈរ និងពីបទអំពើប្រល័យពូជសាសន៍មកលើជនជាតិចាមនៅខេត្តកំពង់ចាម។ ខ្ញុំបានដាក់ អោ អាន ឱ្យស្ថិតក្រោមការពិនិត្យដោយសារតំណែងពីមុនគាត់ជាអនុលេខាភូមិភាគកណ្តាល (ឧត្តរចាស់) ជាសមាជិកនៃគណៈភូមិភាគកណ្តាល(ឧត្តរចាស់) និងជាលេខាតំបន់ ៤១ នៅភូមិភាគកណ្តាល(ឧត្តរចាស់)[6]។

៨. នៅថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១៦ មេធាវីការពារក្តី បានដាក់*សំណើសុំបំពេញកិច្ចស៊ើបសួរលើកទី ១១* (“សំណើទី ១១”)[7]។

## II. **សារណា**

### ក. **សំណើទី ១**

៩. នៅក្នុងសំណើទី ១ មេធាវីការពារក្តី អះអាងថា ភស្តុតាងនៅក្នុងសំណុំរឿង[8] បង្ហាញថា តា ម៉ុក បានកាន់តួនាទីមួយនៅថ្នាក់កំពូលនៃរចនាសម្ព័ន្ធបញ្ជាការរបស់ខ្មែរក្រហម និងមានការគ្រប់គ្រងលើភូមិភាគនិរតី ភូមិភាគកណ្តាល និងភូមិភាគពាយ័ព្យ សម័យកម្ពុជា ប្រជាធិបតេយ្យ[9]។ តាមមេធាវីការពារក្តី ភស្តុតាងនៅក្នុងសំណុំរឿង ក៏បង្ហាញថា តា ម៉ុក អាច មានតួនាទីសំខាន់មួយនៅក្នុងការបោសសម្អាតភូមិភាគកណ្តាលដែលបានចោទ[10]។

១០. ហេតុនេះ មេធាវីការពារក្តី ស្នើ ស.ច.ស សុំបំពេញកិច្ចស៊ើបសួរឱ្យបានពេញលេញអំពីតួនាទីរបស់ តា ម៉ុក នៅក្នុងការបោសសម្អាតភូមិភាគកណ្តាលដែលបានចោទ ដោយស្វែងរក

---

[6]សំណុំរឿង០០៤ ឯកសារD303 *កំណត់ហេតុនៃការបង្ហាញខ្លួនម្តងទៀតរបស់ អោ អាន* ថ្ងៃទី១៤ ខែមីនា ឆ្នាំ ២០១៦។

[7]សំណុំរឿង០០៤ ឯកសារ D317 *សំណើសុំបំពេញកិច្ចស៊ើបសួរលើកទី ១១* ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១៦។

[8]មេធាវីការពារក្តី បញ្ជាក់ថា នៅដំណាក់កាលនេះ ខ្លួនមិនទទួលស្គាល់ហើយក៏មិនបដិសេធព័ត៌មាននៅក្នុងសំណុំរឿងដែរ។

[9]សំណើទី ១ កថាខណ្ឌ ១៩-២២។

[10]ដូចជើងទំព័រខាងលើ កថាខណ្ឌ ២៣-២៦។

និងត្រួតពិនិត្យភស្តុតាងដែលតុលាការយោធាកម្ពុជា("តុលាការយោធា") ប្រមូលបាននៅក្នុងអំឡុងពេលស៊ើបសួរប្រឆាំង តា ម៉ុក រវាងឆ្នាំ ១៩៩៩ ដល់ឆ្នាំ ២០០៦[11]។ មេធាវីការពារក្ដីអះអាងថា កិច្ចស៊ើបសួរនេះគួររាប់បញ្ចូល ប៉ុន្តែមិនកំណត់នៅត្រឹម៖

ក. ការស្នើសុំពីតុលាការយោធា នូវឯកសារទាំងអស់ទាក់ទងនឹងការចាប់ខ្លួន និងការឃុំខ្លួន តា ម៉ុក។

ខ. ការពិនិត្យរាល់ចម្លើយទាំងអស់ដែល តា ម៉ុក បានផ្ដល់ជូនចៅក្រម និងព្រះរាជអាជ្ញារបស់តុលាការយោធា។

គ. ការពិនិត្យសេចក្ដីសម្រេច ដីកា និងការរកឃើញរបស់អាជ្ញាធរតុលាការដែលបានបំពេញកិច្ចស៊ើបសួរប្រឆាំង តា ម៉ុក។

ឃ. សម្ភាសអាជ្ញាធរតុលាការដែលបានស៊ើបអង្កេត តា ម៉ុក[12]។

១១. មេធាវីការពារក្ដី បញ្ជាក់ថា សំណើទី ១ គឺច្បាស់លាស់គ្រប់គ្រាន់ ហើយជាសំណើចាំបាច់ និងពាក់ព័ន្ធនឹងការបញ្ជាក់ពីការពិតនៅក្នុងកិច្ចស៊ើបសួរប្រឆាំង អោ អាន[13]។ មេធាវីការពារក្ដីអះអាងថែមទៀតថា ព័ត៌មានដែលបានស្នើ ទំនងជាទទួលបានភស្តុតាងដោះបន្ទុក ជាពិសេសគឺថា អោ អាន មិនមានសិទ្ធិអំណាចធ្វើសេចក្ដីសម្រេចទាក់ទងនឹងការបោសសម្អាតភូមិភាគកណ្ដាលដែលបានរៀបចំផែនការ និងអនុវត្តមុនពេលដែល អោ អាន មកដល់ភូមិភាគកណ្ដាល[14]។

## ខ. សំណើទី ៨

១២. សំណើទី ៨ គឺផ្អែកលើព័ត៌មានដែលអតីតសហចៅក្រមកាន់តំណែងខ្ញុំ ទទួលបាននៅក្នុងកិច្ចខិតខំប្រឹងប្រែងរបស់គាត់ដើម្បីទទួលបានឯកសារស៊ើបសួរសំណុំរឿង តា ម៉ុក ពីតុលាការយោធា។ ព័ត៌មាននេះបង្ហាញឲ្យឃើញផ្សេងៗ ដូចជា តុលាការយោធា បានបំផ្លាញចោល

[11] ដូចជើងទំព័រខាងលើ កថាខណ្ឌ ១-២, ២៧-២៩។

[12] ដូចជើងទំព័រខាងលើ កថាខណ្ឌ ២, ៣៩។

[13] ដូចជើងទំព័រខាងលើ កថាខណ្ឌ ៤០,៤១។

[14] ដូចជើងទំព័រខាងលើ កថាខណ្ឌ ២, ៤២។

ឯកសារសំណុំរឿង តា ម៉ុក ហើយ ប៉ែនសុន សម៉័យ ជាមេធាវីតំណាង តា ម៉ុក នៅក្នុងកិច្ចស៊ើបសួររបស់តុលាការយោធា អាចមានឯកសារដែលបានរៀបចំឡើងនៅក្នុងអំឡុងពេលស៊ើបសួរនោះ[15]។ ហេតុនេះ មេធាវីការពារក្ដី ស្នើថា ស.ច.ស គួរ៖

ក. កោះហៅ ប៉ែនសុន សម៉័យ ហើយស្ដាប់ចម្លើយគាត់។

ខ. បង្គាប់ឱ្យ ប៉ែនសុន សម៉័យ រៀបចំឯកសារទាំងអស់ដែលគាត់មាន ទាក់ទងនឹងកិច្ចស៊ើបសួរដើម្បីអាចដាក់ចូលក្នុងសំណុំរឿង ០០៤[16]។

១៣. ក្នុងករណីដែល ប៉ែនសុន សម៉័យ បដិសេធមិនគោរពតាមសំណើបែបនេះ មេធាវីការពារក្ដីស្នើថា ស.ច.ស គួរ៖

ក. បង្ខំឱ្យ ប៉ែនសុន សម៉័យ ចូលបង្ហាញខ្លួននៅចំពោះមុខ អ.វ.ត.ក។

ខ. បង្គាប់ឱ្យដកហូតឯកសារទាក់ទងនឹង តា ម៉ុក ដែលប៉ែនសុន សម៉័យ មាន ហើយដាក់ឯកសារទាំងនោះចូលក្នុងសំណុំរឿង[17]។

១៤. មេធាវីការពារក្ដី បញ្ជាក់ថា ខ្លួនមិនស្នើថា ស.ច.ស គួរទទួលបានកំណត់ហេតុនៃការប្រាស្រ័យទាក់ទងគ្នារវាង ប៉ែនសុន សម៉័យ ជាមួយនឹង តា ម៉ុក ឬក៏ឯកសារឯកសិទ្ធិរក្សាការសម្ងាត់ផ្សេងទៀត ទេ ប៉ុន្ដែ គួរទទួលបានឯកសារតុលាការផ្លូវការដែលមិនស្ថិតនៅក្នុងឯកសារឯកសិទ្ធិរក្សាការសម្ងាត់រវាងមេធាវី ជាមួយនឹងកូនក្ដី[18]។

១៥. មេធាវីការពារក្ដីអះអាងថា សំណើទី២នេះ គឺច្បាស់លាស់គ្រប់គ្រាន់ ហើយឯកសារសំណុំរឿង តា ម៉ុក គឺពាក់ព័ន្ធនឹងការចោទប្រកាន់អំពីការបោសសម្អាតភូមិភាគកណ្ដាល ហេតុនេះពាក់ព័ន្ធនឹងកិច្ចស៊ើបសួរប្រឆាំង អោ អាន។ បន្ថែមពីលើនេះទៀត ឯកសារនៅក្នុងសំណុំរឿង តា ម៉ុក

---

[15] សំណើទី ៨ កថាខណ្ឌ ៦-១១។

[16] ដូចដើងទំព័រខាងលើ កថាខណ្ឌ ១, ៣៤។

[17] ដូចដើងទំព័រខាងលើ កថាខណ្ឌ ២, ៣៥។

[18] ដូចដើងទំព័រខាងលើ កថាខណ្ឌ ២៣-២៦។

ទំនងជាទទួលបានភស្តុតាងដោះបន្ទុកទាក់ទងនឹងការចោទប្រកាន់អំពីការចូលរួមរបស់ អោ អាន នៅក្នុងការបោសសម្អាតភូមិភាគកណ្តាល[19]។

**គ. សំណើទី ១១**

១៦. សំណើទី ១១ គឺផ្អែកលើអត្ថបទរបស់សារព័ត៌មាន *ញូយ៉ក ថែមស៍* និងវីដេអូមួយដែលមាននៅក្នុង YouTube ដែលតាមរយៈនេះ នៅឆ្នាំ ១៩៩៩ មជ្ឈមណ្ឌលឯកសារកម្ពុជា បានផ្តល់ភស្តុតាងពាក់ព័ន្ធនឹងកិច្ចស៊ើបសួរសំណុំរឿង តា ម៉ុក ជូនទៅព្រះរាជអាជ្ញាតុលាការយោធាដែលទទួលបន្ទុករឿងក្តី តា ម៉ុក និងជូនទៅ បែនសុន សម័យ ជាមេធាវីរបស់ តា ម៉ុក។ តាមប្រភពឯកសារទាំងនេះ ឯកសារជាច្រើនក្នុងចំណោមឯកសារដែលបានផ្តល់ជូនទាំងនេះគឺមានហត្ថលេខារបស់ តា ម៉ុក[20]។

១៧. មេធាវីការពារក្តី ស្នើថា ស.ច.ស គួរបង្គាប់ឱ្យមជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវ៖

ក. ប្រគល់ជូន ស.ច.ស នូវសំណៅនៃឯកសារទាំងអស់ដែលបានដាក់បង្ហាញជូនព្រះរាជអាជ្ញា និងមេធាវីការពារក្តី តា ម៉ុក។

ខ. ប្រគល់ជូន ស.ច.ស នូវកំណត់ហេតុផ្សេងទៀតដែលមជ្ឈមណ្ឌលឯកសារកម្ពុជា មានទាក់ទងនឹងកិច្ចស៊ើបសួរសំណុំរឿង តា ម៉ុក។

គ. បង្ហាញអត្តសញ្ញាណបុគ្គលផ្សេងទៀត ឬស្ថាប័នដែលអាចមានឯកសារពាក់ព័ន្ធនឹងកិច្ចស៊ើបសួរសំណុំរឿង តា ម៉ុក។

ឃ. ដាក់ឯកសារដែលទទួលបានដោយសារកិច្ចស៊ើបសួរនេះចូលក្នុងសំណុំរឿង[21]។

១៨. មេធាវីការពារក្តី អះអាងថា សំណើទី ១១ គឺច្បាស់លាស់គ្រប់គ្រាន់ ពាក់ព័ន្ធនឹងកិច្ចស៊ើបសួរសំណុំរឿង ០០៤ ហើយកិច្ចស៊ើបសួរដែលបានស្នើសុំឱ្យបំពេញ ទំនងជាទទួលបានភស្តុតាងដោះបន្ទុកសម្រាប់ អោ អាន[22]។

---

[19]ដូចជើងទំព័រខាងលើ កថាខណ្ឌ ២៩-៣២។

[20]ដូចជើងទំព័រខាងលើ កថាខណ្ឌ ៧-៨ ។

[21]ដូចជើងទំព័រខាងលើ កថាខណ្ឌ ២, ១៦។

01340685



## III. ពិភាក្សា

១៩. ជាគោលការណ៍ សំណើទី ១ ទី ៨ និងទី ១១ មានកម្មវត្ថុដូចគ្នាគឺ ត្រូវស៊ើបសួរអំពីតួនាទីរបស់ តា ម៉ុក នៅក្នុងឧក្រិដ្ឋកម្មដែលសហព្រះរាជអាជ្ញាអន្តរជាតិ បានចោទ អោ អាន។ ហេតុនេះ ខ្ញុំនឹងធ្វើសេចក្ដីសម្រេចរួមលើសំណើទាំងនេះនៅក្នុងដីកាសម្រេចនេះ។

### ក. បទដ្ឋានសម្រាប់វាយតម្លៃសំណើសុំបំពេញកិច្ចស៊ើបសួរ

២០. អង្គបុរេជំនុំជម្រះ ("អ.ប.ជ") ធ្លាប់បានបញ្ជាក់ថា ភាគីដែលស្នើសុំបំពេញកិច្ចស៊ើបសួរ"*ត្រូវបំពេញលក្ខខណ្ឌត្រួតលើគ្នាចំនួនពីរ [...] ពោលគឺ សំណើសុំត្រូវតែ៖*

*(១) កំណត់បង្ហាញអំពីសកម្មភាពដែលត្រូវធ្វើ ឬដីកាដែលត្រូវធ្វើ ដោយមានការបញ្ជាក់ឱ្យបានច្បាស់លាស់("លក្ខខណ្ឌនៃភាពច្បាស់លាស់")*

*(២) បង្ហាញឱ្យបានពិស្តារអំពីមូលហេតុអ្វីបានជាសំណើបំពេញកិច្ចស៊ើបសួរដែលបានស្នើសុំ ឬកិច្ចដែលកើតចេញមកពីដីកាដែលធ្វើឡើង [...]មានការ"ពាក់ព័ន្ធទៅនឹងការបញ្ជាក់នូវការពិត"ជាបឋម(លក្ខខណ្ឌនៃភាពពាក់ព័ន្ធជាបឋម)*"[23]។

២១. លក្ខខណ្ឌនៃភាពច្បាស់លាស់ តម្រូវឱ្យភាគីដែលស្នើ ជាប់កាតព្វកិច្ច"*ត្រូវមានភាពច្បាស់លាស់គ្រប់គ្រាន់ដើម្បីធ្វើការបង្ហាញឱ្យបានច្បាស់លាស់ដល់សហចៅក្រមស៊ើបអង្កេត ពាក់ព័ន្ធនឹងកិច្ចការអ្វីដែលសហចៅក្រមស៊ើបអង្កេតត្រូវធ្វើការស៊ើបសួរ*"[24]។ ហេតុនេះ ខ្ញុំមិនជាប់លក្ខខណ្ឌត្រូវអនុញ្ញាតតាមសំណើមានលក្ខណៈជាទូទៅ ឬប៉ាន់ស្មាន ដែលស្នើសុំស្វែងរកភស្តុតាងដោះបន្ទុកឡើយ[25]។ ប៉ុន្តែ ភាគីដែលស្នើ ត្រូវតែចង្អុលបង្ហាញឱ្យបានច្បាស់លាស់អំពីវត្តមាននៃ

---

[22]ដូចជើងទំព័ខាងលើ កថាខណ្ឌ ១២-១៥។

[23]សំណុំរឿង ០០២ ឯកសារ D365/2/17 *សាលដីកាស្ដីពីការពិចារណាឡើងវិញទៅលើបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតទៅលើសំណើសុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿងដែលនឹងជួយដល់ការបញ្ជាក់ពីការដឹងឮរបស់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង* ("សាលដីកាស្ដីពីការពិចារណាឡើងវិញ") ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ២០១០ កថាខណ្ឌ ៤៧។

[24]សាលដីកាស្ដីពីការពិចារណាឡើងវិញ កថាខណ្ឌ ៤៨។

[25]ដូចជើងទំព័រខាងលើ កថាខណ្ឌ ៤៨ និង ៥១។

ភស្តុតាងដែលត្រូវស្វែងរក[26]។ ឧទាហរណ៍ អ.ប.ជ បានសម្រេចថា សំណើសុំដែលមិនបានលើកឡើងច្បាស់លាស់អំពីចំនួនឯកសារ ឬអំពីទីតាំងច្បាស់លាស់ដែលប្រមូលបានឯកសារនោះ ឬទីតាំងទុកដាក់ឯកសារនោះ គឺខកខានមិនបានបំពេញលក្ខខណ្ឌនៃភាពច្បាស់លាស់ឡើយ[27]។

២២. លក្ខខណ្ឌនៃភាពពាក់ព័ន្ធ មានលក្ខខណ្ឌរងចំនួនពីរ។ ទី ១ សំណើ ត្រូវ"*មានការពាក់ព័ន្ធជាមួយនឹងវិសាលភាពនៃការស៊ើបសួរ អនុលោមតាមការកំណត់ និងព្រំដែនដែលបានកំណត់ដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម*"[28]។ ទី ២ សំណើ "*ត្រូវរៀបរាប់លម្អិតអំពីមូលហេតុអ្វីបានជាកិច្ចស្នើដែលជាកម្មវត្ថុនៃដីកាសម្រេចនឹងនាំឱ្យរកឃើញនូវការពិត*"[29]។ លក្ខខណ្ឌនេះតម្រូវថា ភាគីដែលស្នើសុំ ត្រូវបញ្ជាក់ពីចំណងទាក់ទងជាបឋមរវាងកិច្ចស៊ើបសួរដែលបានស្នើសុំ ជាមួយនឹងបញ្ហាដែលស្ថិតនៅក្នុងវិសាលភាពនៃកិច្ចស៊ើបសួរ[30]។ ក្នុងករណីដែលសំណើពាក់ព័ន្ធនឹងភស្តុតាងដោះបន្ទុក ភាគីដែលស្នើសុំត្រូវបង្ហាញពីមូលហេតុជាបឋមដែលថា ការបំពេញកិច្ចស៊ើបសួរអាចនាំឱ្យមានភស្តុតាងដោះបន្ទុក[31]។

---

[26]សំណុំរឿង០០២ ឯកសារ D100/9/2 *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតទៅលើសំណើលើកទីពីររបស់ នួន ជា សុំបំពេញកិច្ចស៊ើបសួរ* ថ្ងៃទី០៥ ខែ ឧសភា ឆ្នាំ ២០១០ កថាខណ្ឌ ៣១។ សំណុំរឿង០០២ ឯកសារD164/4/13*សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួមរបស់សហចៅក្រមស៊ើបអង្កេតទៅលើសំណើលើកទីពីររបស់ នួន ជា សុំបំពេញកិច្ចស៊ើបសួរ* ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៩ កថាខណ្ឌ ៣៩។ សំណុំរឿង០០២ ឯកសារ D273/3/5 *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ ក.ស.ច.ស លើសំណើលើកទី ១៨ របស់ នួន ជា សុំបំពេញកិច្ចស៊ើបសួរ* ថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០១០។ សាលដីកាស្តីពីការពិចារណា ឡើងវិញ កថាខណ្ឌ ៤៨ និង៧៣។ សំណុំរឿង០០២ ឯកសារ D164/3/6 *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម* ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៩ កថាខណ្ឌ ៤៣។

[27]សាលដីកាស្តីពីការពិចារណាឡើងវិញ កថាខណ្ឌ ៤៨។

[28]ដូចជើងទំព័រខាងលើ កថាខណ្ឌ ៤៩។

[29]ដូចជើងទំព័រខាងលើ កថាខណ្ឌ ៥០។

[30]ដូចជើងទំព័រខាងលើ កថាខណ្ឌ ៥០-៥១។

[31]សំណុំរឿង០០២ ឯកសារ D353/2/3 *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី អៀងធីរិទ្ធ ប្រឆាំងនឹង "ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួររបស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ"ចុះថ្ងៃទី ១៥ ខែមីនា ឆ្នាំ ២០១០* ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១០ កថាខណ្ឌ ៤៧។

01340687



## ខ. វិភាគសំណើទី ១ និងទី ៨

២៣. ដោយផ្អែកលើភស្តុតាងដែលបានបង្ហាញរហូតមកដល់សព្វថ្ងៃនេះនៅក្នុងកិច្ចស៊ើបសួរអំពីតំណែង និងតួនាទីរបស់ តា ម៉ុក នៅភូមិភាគកណ្តាល នៅពេលវេលាដែលពាក់ព័ន្ធនឹងការចោទប្រកាន់មកលើ អោ អាន ទើបខ្ញុំជឿជាក់ថា ឯកសារដែលបានរៀបចំឡើងដោយតុលាការយោធា នៅក្នុងកិច្ចស៊ើបសួរប្រឆាំង តា ម៉ុក ("ឯកសារសំណុំរឿង តា ម៉ុក") ស្លាប់នៅថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០៦[32] អាចមានព័ត៌មានពាក់ព័ន្ធនឹងកិច្ចស៊ើបសួរប្រឆាំង អោ អាន។ ហេតុនេះ សំណើទី ១ និង ៨ បំពេញតាមលក្ខខណ្ឌនៃភាពពាក់ព័ន្ធជាបឋម។ មេធាវីការពារក្តី ក៏បង្ហាញបានច្បាស់លាស់គ្រប់គ្រាន់អំពីកិច្ចស៊ើបសួរដែលខ្លួន ស្នើសុំ ស.ច.ស ឲ្យបំពេញ ។

២៤. រហូតមកដល់សព្វថ្ងៃនេះ ការិយាល័យសហចៅក្រមស៊ើបអង្កេត ("ក.ស.ច.ស") បានព្យាយាមជាច្រើនដងដើម្បីទទួលបានឯកសារសំណុំរឿង តា ម៉ុក ស្វែងរក និងស្តាប់ចម្លើយជនដែលធ្លាប់ធ្វើការងារពាក់ព័ន្ធនឹងកិច្ចស៊ើបសួរសំណុំរឿង តា ម៉ុក។ ការព្យាយាមទាំងនេះបានចាប់ផ្តើមធ្វើឡើងមុនពេលដែលដាក់សំណើទី ១ ទៀត។ ប៉ុន្តែ ការព្យាយាមទាំងនេះមិនទទួលបានលទ្ធផលទេ។

i. <u>ទំនាក់ទំនងជាមួយនឹងតុលាការយោធា</u>

២៥. នៅថ្ងៃទី០៩ ខែ តុលា ឆ្នាំ ២០១៣ អតីតសហចៅក្រមកាន់តំណែងខ្ញុំ បានសរសេរលិខិតជូនចៅក្រមន័យ ថុល ប្រធានតុលាការយោធា ទាក់ទងនឹងការផ្តល់ឯកសារសំណុំរឿងតា ម៉ុក[33]។ ចៅក្រម ន័យ ថុល បានឆ្លើយតបនៅថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ដោយបញ្ជាក់ថា តុលាការយោធា ធ្លាប់មានឯកសារសំណុំរឿង តា ម៉ុក ប៉ុន្តែ បានបំផ្លាញវាចោល បន្ទាប់ពី តា ម៉ុក ស្លាប់នៅឆ្នាំ ២០០៦[34]។

---

[32] សំណុំរឿង០០៤ ឯកសារ D246.1.4 *ការឆ្លើយតបទី ២ ពីចៅក្រម ន័យ ថុល ផ្ញើជូនចៅក្រម Mark Harmon អំពីឯកសារសំណុំរឿង តា ម៉ុក របស់តុលាការយោធា* ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥។

[33] សំណុំរឿង០០៤ ឯកសារ D246.1.1 *លិខិតទី ១ ពីចៅក្រម Mark Harmon ផ្ញើជូនចៅក្រម ន័យ ថុល អំពីឯកសារសំណុំរឿង តា ម៉ុក របស់តុលាការយោធា* ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១៣។

[34] សំណុំរឿង០០៤ ឯកសារ D246.1.2 *ការឆ្លើយតបទី ១ ពីចៅក្រម ន័យ ថុល ផ្ញើជូនចៅក្រម Mark Harmon អំពីឯកសារសំណុំរឿង តា ម៉ុក របស់តុលាការយោធា* ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣។

២៦. បន្ទាប់ពីមេធាវីការពារក្តី បានដាក់សំណើទី ១ អតីតសហចៅក្រមកាន់តំណែងខ្ញុំ បានសរសេរលិខិតទី ២ ជូនចៅក្រម ន័យ ធុល ដោយស្នើសុំការបញ្ជាក់បំភ្លឺថាតើ មានបណ្តសារនៃឯកសារសំណុំរឿងដែលបានបំផ្លាញចោលនោះដែរឬអត់។ អតីតសហចៅក្រមកាន់តំណែងខ្ញុំក៏បានស្នើសុំឈ្មោះបុគ្គលដែលជាប់ពាក់ព័ន្ធនឹងកិច្ចស៊ើបសួរសំណុំរឿងតា ម៉ុក ហើយបានភ្ជាប់ជូននូវអត្ថបទសារព័ត៌មានមួយចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០១ ដែលបង្ហាញថា ងិន សំអាន គឺជាចៅក្រមស៊ើបសួរទទួលបន្ទុកកិច្ចស៊ើបសួរនេះ ហើយតាមសេចក្តីរាយការណ៍គាត់បានសួរចម្លើយ តា ម៉ុក ជាច្រើនដង[35]។

២៧. នៅថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥ ចៅក្រម ន័យ ធុល បានជូនដំណឹងអតីតសហចៅក្រមកាន់តំណែងខ្ញុំ ថា តា ម៉ុក ត្រូវបានតុលាការយោធា ស៊ើបអង្កេតពីឆ្នាំ ១៩៩៩ រហូតដល់ពេលគាត់ស្លាប់នៅឆ្នាំ ២០០៦ ប៉ុន្តែ ឯកសារសំណុំរឿង តា ម៉ុក លែងមាននៅតុលាការទៀតហើយ ហើយក៏មិនមាននៅក្នុងបណ្ណសាររបស់តុលាការដែរ។ ចៅក្រម ន័យ ធុល ក៏បានបញ្ជាក់ថា ងិន សំអាន បានទទួលបន្ទុកការស៊ើបសួររឿងក្តី តា ម៉ុក ហើយ ប៉ែនសុន សម័យ គឺជាមេធាវីការពារក្តី តា ម៉ុក។ គាត់ក៏បានបញ្ជាក់ថា ងិន សំអាន ពិបាកនិយាយស្តី និងពិបាកធ្វើដំណើរ ហើយកំពុងស្ថិតក្នុងការព្យាបាល[36]។ មិនមានការផ្តល់ព័ត៌មានទាក់ទងនឹងឈ្មោះ សោ សុខ ជាមេធាវីដែលសារព័ត៌មាន*ភ្នំពេញ ប៉ុស្តិ៍* បង្ហាញថាជាព្រះរាជអាជ្ញា នៅក្នុងកិច្ចស៊ើបសួរសំណុំរឿង តា ម៉ុក[37]។

---

[35]សំណុំរឿង០០៤ ឯកសារ D246.1.3 *លិខិតទី ២ ពីចៅក្រម Mark Harmon ផ្ញើជូនចៅក្រម ន័យ ធុល អំពីឯកសារសំណុំរឿង តា ម៉ុក របស់តុលាការយោធា* ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១៥។ សំណុំរឿង០០៤ ឯកសារ D246.1.3.1 *ការស៊ើបអង្កេត ឌុច និង តា ម៉ុក មិនទាន់បន្តដំណើរការ* ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០១។

[36]សំណុំរឿង០០៤ ឯកសារ D246.1.4 *ការឆ្លើយតបទី ២ ពីចៅក្រម ន័យ ធុល ផ្ញើជូនចៅក្រម Mark Harmon អំពីឯកសារសំណុំរឿង តា ម៉ុក របស់តុលាការយោធា* ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រ ១។ សំណុំរឿង០០៤ ឯកសារ D246 *កំណត់ហេតុនៃកិច្ចស៊ើបសួរ* ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥។

[37]សំណុំរឿង០០៤ ឯកសារ D246.1.3.1 *ការស៊ើបអង្កេត ឌុច និង តា ម៉ុក មិនទាន់បន្តដំណើរការ* ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០១ ក៏អាចចូលមើលបានតាមរយៈ http://www.phnompenhpost.com/national/duch-and-ta-mok-investigations-ice។

២៨. នៅថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៥ ខ្ញុំបានសរសេរលិខិតជូនប្រធានតុលាការយោធា ដោយស្នើសុំព័ត៌មានអំពីទីកន្លែង និងឋានៈរបស់ សោ សុខ[38]។ នៅថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៥ ប្រធានតុលាការយោធា បានឆ្លើយតបថា គាត់មិនមានព័ត៌មានអំពី សោ សុខ ទេ[39]។ ការព្យាយាមដើម្បីទទួលបានព័ត៌មានទំនាក់ទំនង សោ សុខ នៅលើគេហទំព័ររបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ក៏មិនទទួលបានលទ្ធផលដែរ[40]។

ii. <u>ទំនាក់ទំនងជាមួយនឹង ប៉ែនសុន សម័យ</u>

២៩. នៅថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៥ អ្នកស៊ើបអង្កេតម្នាក់របស់ ក.ស.ច.ស ដោយមានជំនួយពីអ្នកបកប្រែភាសា បានទូរសព្ទទៅ ប៉ែនសុន សម័យ ហើយបានសួរគាត់ថាតើ គាត់មានកំណត់ហេតុចម្លើយរបស់ តា ម៉ុក នៅពេលដែលគាត់ស្ថិតនៅក្រោមការស៊ើបអង្កេត ដែរឬអត់។ ប៉ែនសុន សម័យ បានឆ្លើយតបថា គាត់មានឯកសាររាប់ពាន់ទំព័រទាក់ទងនឹង តា ម៉ុក ពីព្រោះថា គាត់គឺជាមេធាវីរបស់ តា ម៉ុក អស់រយៈពេល ៨ ឆ្នាំ។ គាត់បានបញ្ជាក់ថា ក.ស.ច.ស គួរធ្វើការណាត់ជួបជាមួយគាត់ដើម្បីពិភាក្សារឿងនេះ ដោយគិតតម្លៃ ៨00 ដុល្លារក្នុងមួយម៉ោង។ បើមិនដូច្នេះទេ គាត់ស្នើសុំឱ្យតែងតាំងគាត់នៅក្នុងតំណែងណាមួយ នៅ អ.វ.ត.ក[41]។

៣០. នៅថ្ងៃទី២១ ខែ ធ្នូ ឆ្នាំ ២០១៥ ខ្ញុំបានសរសេរលិខិតទៅ ប៉ែនសុន សម័យ ដោយស្នើគាត់ឱ្យផ្តល់ជូន ក.ស.ច.ស នូវឯកសារណាដែលគាត់មានទាក់ទងនឹងកិច្ចស៊ើបសួរសំណុំរឿង តា ម៉ុក ក្រៅពីឯកសារដែលស្ថិតក្នុងឯកសិទ្ធិរក្សាការសម្ងាត់រវាងមេធាវី ជាមួយនឹងកូនក្តី[42]។

---

[38]ឧបសម្ព័ន្ធក៖ លិខិតពីចៅក្រម Michael Bohlander ផ្ញើជូនចៅក្រមន័យ ធុល អំពី*សំណើសុំការជួយជ្រៀមជ្រែងបន្ថែម* ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៥។

[39]ឧបសម្ព័ន្ធ ខ៖ លិខិតពីចៅក្រម ន័យ ធុល ផ្ញើជូនចៅក្រម Michael Bohlander *លិខិតសំណើសុំការជួយជ្រៀមជ្រែងបន្ថែមរបស់ចៅក្រម Michael Bohlander ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៥* ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៥។

[40]សូមមើល http://www.bakc.org.kh/index.php/memberships.។

[41]សំណុំរឿង00៤ ឯកសារ D219/389 *កំណត់ហេតុនៃកិច្ចស៊ើបសួរ* ថ្ងៃទី 0១ ខែ កក្កដា ឆ្នាំ ២០១៥។ ឧបសម្ព័ន្ធ ឆ៖ សេចក្តីបញ្ជាក់របស់ Julie Bardèche និងគឺ កណ្ណិកា ចុះថ្ងៃទី 0៦ ខែ ឧសភា ឆ្នាំ ២០១៦។

[42]ឧបសម្ព័ន្ធ គ៖ លិខិតពីចៅក្រម Michael Bohlander ផ្ញើជូនប៉ែនសុន សម័យ អំពី *សំណើសុំផ្តល់ឯកសារដែលបានធ្វើឡើងនៅក្នុងកិច្ចដំណើរការនីតិវិធីប្រឆាំងតា ម៉ុក នៅចំពោះមុខតុលាការយោធានៃកងយុទ្ធពលខេមរភូមិន្ទ* ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៥។

ដោយមិនទទួលបានការឆ្លើយតបពីបែនសុន សម័យ ទើបខ្ញុំផ្ញើជូនគាត់ នូវលិខិតបន្ទាប់មកទៀត ចុះថ្ងៃទី ១៧ ខែ កុម្ភៈ និងថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១៦ ដោយបង្ហាញថា ខ្ញុំនឹងចាត់នីតិវិធីតាមច្បាប់តម្រូវ ដោយមិនជូនដំណឹងថែមទៀតឡើយ ប្រសិនបើគាត់មិនផ្តល់ជូនខ្ញុំនូវឯកសារដែលបានស្នើ នៅត្រឹមកាលបរិច្ឆេទដូចបានបញ្ជាក់នៅក្នុងលិខិតរបស់ខ្ញុំ[43]។ បុគ្គលិកការិយាល័យរបស់បែនសុន សម័យ បានបដិសេធមិនព្រមទទួលយកលិខិតរបស់ខ្ញុំ ចុះថ្ងៃទី ១៧ ខែ កុម្ភៈ និងថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១៦[44]។

៣១. នៅថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៦ ខ្ញុំបានទទួលការឆ្លើយតបពី បែនសុន សម័យ ដោយបញ្ជាក់ថា គាត់បានបាត់ឯកសារដែលបានស្នើទាំងនោះហើយ ហេតុនេះ មិនអាចបំពេញតាមសំណើរបស់ខ្ញុំបានឡើយ។ គាត់បានបញ្ជាក់ថា ឯកសារទាំងអស់ដែលពាក់ព័ន្ធនឹងកិច្ចស៊ើបសួរសំណុំរឿងតា ម៉ុក គឺរក្សាទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា និងតុលាការយោធា ហើយបានលើកឡើងថា ខ្ញុំគួរស្នើសុំឯកសារទាំងនោះពីស្ថាប័នទាំងនេះ[45]។ការប្រាស្រ័យទាក់ទងរវាង ក.ស.ច.ស ជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា នឹងត្រូវពិភាក្សានៅក្នុងការវិភាគសំណើទី ១១ នៅខាងក្រោមនេះ។

៣២. នៅថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១៦ ខ្ញុំបានដាក់ពាក្យបណ្តឹងទៅប្រធានគណៈមេធាវី ប្តឹងបែនសុន សម័យ ចំពោះបញ្ហាខ្វះកិច្ចសហការជាមួយនឹង អ.វ.ត.ក និងការគោរពវិជ្ជាជីវៈ។ ជាពិសេស ខ្ញុំបានបង្ហាញសេចក្តីព្រួយបារម្ភរបស់ខ្ញុំថា បុគ្គលការិយាល័យរបស់ បែនសុន សម័យ បានបដិសេធពីរដងមិនព្រមទទួលយកលិខិតឆ្លើយឆ្លងផ្លូវការរបស់តុលាការ បែនសុន សម័យ បានព្យាយាមស្វែងរកប្រាក់កម្រៃ និង/ឬការងារ នៅ អ.វ.ត.ក ជាថ្នូរនឹងការផ្តល់ឯកសារដែលគាត់មានកាតព្វកិច្ចត្រូវប្រគល់ឱ្យ ជាភស្តុតាងនៅក្នុងកិច្ចស៊ើបសួររបស់តុលាការ ហើយខ្ញុំមានមូលហេតុជឿថា បែនសុន សម័យ មិនមានភាពស្មោះត្រង់ទាក់ទងនឹងឯកសារ

---

[43]ឧបសម្ព័ន្ធ ឃ៖ លិខិតពីចៅក្រម Michael Bohlander ផ្ញើជូនបែនសុន សម័យ អំពី *សំណើសុំផ្តល់ឯកសារ* ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០១៦។ ឧបសម្ព័ន្ធ ង៖ លិខិតពីចៅក្រម Michael Bohlander ផ្ញើជូនបែនសុន សម័យ អំពី *សំណើសុំផ្តល់ឯកសារ* ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១៦។

[44]សូមមើល ឧបសម្ព័ន្ធ ជ៖ លិខិតពីចៅក្រម Michael Bohlander ផ្ញើជូនលោក ប៊ុន ហុន អំពី *ពាក្យបណ្តឹងប្តឹងលោក បែនសុន សម័យ ដោយសារមិនសហការជាមួយ អ.វ.ត.ក* ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១៦។

[45]សូមមើល ឧបសម្ព័ន្ធ ច៖ លិខិតពីលោកបែនសុន សម័យ ផ្ញើជូនចៅក្រម Michael Bohlander អំពី *ករណីស្នើសុំឱ្យផ្តល់ឯកសារនៃសំណុំរឿងរបស់ ជួន ជឿន (តា ម៉ុក)* ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៦។

01340691



ដែលគាត់មាន ដោយពិនិត្យឃើញថា គាត់បានផ្តល់ចម្លើយចំនួនពីរមិនស៊ីសង្វាក់គ្នាអំពីបញ្ហានេះ[46]។

៣៣. នៅថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៦ លោក ប៊ុន ហុន ប្រធានគណៈមេធាវី បានជូនដំណឹងខ្ញុំថា ក្រុមប្រឹក្សាគណៈមេធាវី កំពុងចាត់វិធានការតាមនីតិវិធីបន្តចំពោះលោក បែនសុន សម័យ ហើយនឹងចេញសេចក្តីសម្រេចលើបញ្ហានេះក្នុងពេលឆាប់ៗខាងមុខនេះ[47]។

៣៤. នៅថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦ លោក ប៊ុន ហុន បានជូនដំណឹងខ្ញុំ ថា បែនសុន សម័យ មិនបានមកបង្ហាញខ្លួននៅក្នុងកិច្ចប្រជុំជាមួយនឹងគណៈមេធាវី ដើម្បីបញ្ជាក់បំភ្លឺបញ្ហានៅក្នុងលិខិតរបស់ខ្ញុំ ដោយសារគាត់មានជំងឺ ដែលតម្រូវឱ្យគាត់ត្រូវព្យាបាលនៅក្រៅប្រទេស ប៉ុន្តែគាត់បានផ្តល់ជូនគណៈមេធាវី នូវលិខិតមួយច្បាប់ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៦ ជាការឆ្លើយតបទៅនឹងបញ្ហានានាដែលខ្ញុំបានលើកឡើងប្តឹងទៅគណៈមេធាវី[48]។ នៅក្នុងលិខិតនោះ បែនសុន សម័យ បានបញ្ជាក់ថា គាត់បានបាត់ឯកសារទាក់ទងនឹង តា ម៉ុក ដោយសារថាសំណុំរឿងបានបិទកាលពី ២០ ឆ្នាំមុន ហើយបានបដិសេធថាគាត់មិនបានដាក់លក្ខខណ្ឌស្នើសុំប្រាក់កម្រៃ ឬការងារ ដើម្បីផ្តល់ឯកសារសំណុំរឿងតា ម៉ុក ជូនទៅ អ.វ.ត.ក ឡើយ[49]។

៣៥. នៅថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៦ ខ្ញុំបានចេញដីកាកោះហៅ បែនសុន សម័យ ឱ្យចូលបង្ហាញខ្លួននៅ អ.វ.ត.ក ដើម្បីស្តាប់ចម្លើយនៅអ.វ.ត.ក[50]។ បែនសុន សម័យ បានបដិសេធ

---

[46]ឧបសម្ព័ន្ធ ជ៖ លិខិតពីចៅក្រម Michael Bohlander ផ្ញើជូនលោក ប៊ុន ហុន អំពី*ពាក្យបណ្តឹងប្តឹងលោក បែនសុន សម័យ ដោយសារមិនសហការជាមួយ អ.វ.ត.ក* ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១៦។

[47]ឧបសម្ព័ន្ធ ឈ ៖ លិខិតពីលោក ប៊ុន ហុន ផ្ញើជូនចៅក្រម Michael Bohlander អំពី *ការពិនិត្យលើពាក្យបណ្តឹងប្តឹងលោកមេធាវី បែនសុន សម័យ ដោយសារមិនសហការជាមួយ អ.វ.ត.ក* ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៦។

[48]ឧបសម្ព័ន្ធ ញ ៖ លិខិតពីលោក ប៊ុន ហុន ផ្ញើជូនចៅក្រម Michael Bohlander អំពី *ការពិនិត្យលើពាក្យបណ្តឹងប្តឹងលោកមេធាវី បែនសុន សម័យ ដោយសារមិនសហការជាមួយ អ.វ.ត.ក* ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦។

[49]ឧបសម្ព័ន្ធ ដ៖ លិខិតពីលោក បែនសុន សម័យ ផ្ញើជូនលោក ប៊ុន ហុន អំពី *លិខិតអញ្ជើញលេខ៖១៦២២/គ.ម/១៦ ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៦ របស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា* ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៦។

[50]ឧបសម្ព័ន្ធ ឋ៖ ដីកាកោះសាក្សីបែនសុន សម័យ ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៦។

មិនទទួលយកដីកាកោះប្រគល់ដោយអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ហើយបានបញ្ជាក់ថា គាត់មិនមានបំណងផ្តល់ការស្តាប់ចម្លើយនៅផ្ទះរបស់គាត់ ឬការិយាល័យរបស់គាត់ទេ[51]។

iii. <u>សេចក្តីសន្និដ្ឋានអំពីសំណើទី ១ និង ទី ៨</u>

៣៦. ដូចបានពន្យល់ខាងលើ ក.ស.ច.ស បានព្យាយាមជាច្រើនដងដើម្បីទទួលបានឯកសារសំណុំរឿង តា ម៉ុក ពីតុលាការយោធា និងដើម្បីស្តាប់ចម្លើយអាជ្ញាធរតុលាការ ដែលធ្លាប់ពាក់ព័ន្ធនឹងកិច្ចស៊ើបសួរនេះ។ ប៉ុន្តែ តុលាការយោធា លែងមានឯកសារសំណុំរឿងនេះទៀតហើយ ចៅក្រមស៊ើបសួរ មិនមានសុខភាពល្អដើម្បីផ្តល់ការស្តាប់ចម្លើយ ហើយព្រះរាជអាជ្ញា មិនអាចរកឃើញ។ បែនសុន សម័យ មេធាវីការពារក្តី តា ម៉ុក មិនមានបំណងឱ្យស្តាប់ចម្លើយ ហើយទោះបីជាពីដំបូង គាត់បានបញ្ជាក់ថា គាត់មានឯកសារពីកិច្ចស៊ើបសួរសំណុំរឿង តា ម៉ុក ក៏ដោយ ក៏ក្រោយមក គាត់បានបដិសេធវិញ។

៣៧. យោងតាមវិធានផ្ទៃក្នុង ៦០(៣) ខ្ញុំអាចព្យាយាមឱ្យ បែនសុន សម័យ ចូលបង្ហាញខ្លួនបានដោយមានជំនួយពីនគរបាលយុត្តិធម៌។ ប៉ុន្តែ តាមទង្វើរបស់ បែនសុន សម័យ រហូតមកដល់សព្វថ្ងៃនេះ ចម្លើយមិនស៊ីសង្វាក់គ្នារបស់គាត់ និងកាយវិការមិនសហការរបស់គាត់ជាមួយនឹង ក.ស.ច.ស ទើបបង្ហាញថា គាត់អាចជាសាក្សីអរិភាព។ តាមកាលៈទេសៈទាំងនេះ ខ្ញុំមិនជឿថា មានមូលហេតុសមហេតុផលដែលត្រូវប្រើប្រាស់មធ្យោបាយចាប់បង្ខំដើម្បីព្យាយាមស្តាប់ចម្លើយ បែនសុន សម័យ ឡើយ។

៣៨. ស្រដៀងគ្នានេះដែរ ខ្ញុំមិនជឿថាចាំបាច់ត្រូវចេញដីកាបង្គាប់ឱ្យឆែកឆេរការិយាល័យរបស់គាត់ដែរ។ តាមរយៈការប្រាស្រ័យទាក់ទងគ្នាជាមួយនឹងបែនសុន សម័យ ដូចបានរៀបរាប់ខាងលើ ជាពិសេស ចម្លើយនាពេលថ្មីៗនេះរបស់គាត់ដែលថា គាត់លែងមានឯកសារទាក់ទងនឹង តា ម៉ុក ទៀតហើយ គឺជាលទ្ធភាពខ្ពស់ដែលបង្ហាញថា ការឆែកឆេរបែបនេះនឹងមិនអាចរកឃើញឯកសារពាក់ព័ន្ធឡើយ។ លទ្ធភាពទាបដែលអាចរកឃើញឯកសារពាក់ព័ន្ធ ត្រូវយកមកពិចារណាថ្លឹងថ្លែងជាមួយនឹងលក្ខណៈបញ្ហានៃការចេញដីកាបង្គាប់ឱ្យឆែកឆេរការិយាល័យ

[51] ឧបសម្ព័ន្ធ ខ៖ អង្គភាពគាំពារសាក្សី និងអ្នកជំនាញ របាយការណ៍ពីកើត សុខា អំពី បែនសុន សម័យ ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៦។

របស់ មេធាវី ជាពិសេសនៅក្នុងកាលៈទេសៈ ដែលមេធាវី និងបុគ្គលិករបស់គាត់ មិនបានសហការជាមួយនឹង អ.វ.ត.ក រហូតមកដល់សព្វថ្ងៃនេះ។

៣៩. ហេតុនេះ ខ្ញុំជឿថា ក.ស.ច.ស បានធ្វើការខិតខំប្រឹងប្រែងសមហេតុផលអស់ហើយដើម្បីទទួលបានឯកសារសំណុំរឿង តា ម៉ុក និងដើម្បីស្តាប់ចម្លើយចៅក្រម ព្រះរាជអាជ្ញា និងមេធាវីការពារក្តី ដែលបានពាក់ព័ន្ធនឹងកិច្ចស៊ើបសួរនេះ។

## គ. ការវិភាគសំណើទី ១១

៤០. តាមសំអាងហេតុដដែលដូចបានបញ្ជាក់ខាងលើចំពោះសំណើសុំឯកសារសំណុំរឿង តា ម៉ុក [52] ឯកសារដែលមជ្ឈមណ្ឌលឯកសារកម្ពុជា មានពាក់ព័ន្ធនឹងកិច្ចស៊ើបសួរសំណុំរឿង តា ម៉ុក អាចមានព័ត៌មានពាក់ព័ន្ធនឹងកិច្ចស៊ើបសួរប្រឆាំង អោ អាន។ ហេតុនេះ ខ្ញុំជឿថា សំណើទី ១១ បំពេញតាមលក្ខខណ្ឌនៃភាពពាក់ព័ន្ធជាបឋម។ មេធាវីការពារក្តី ក៏បង្ហាញបានច្បាស់លាស់គ្រប់គ្រាន់អំពីកិច្ចស៊ើបសួរដែលខ្លួន ស្នើសុំ ស.ច.ស ឱ្យបំពេញ។

៤១. នៅថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០១៦ អ្នកវិភាគរបស់ ក.ស.ច.ស បានធ្វើការស្រាវជ្រាវបណ្ណសារតាមអ៊ីនធើណែតរបស់ មជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីស្វែងរកឯកសារពាក់ព័ន្ធនឹងកិច្ចស៊ើបសួរសំណុំរឿងតា ម៉ុក ប៉ុន្តែ មិនអាចរកឃើញឯកសារពាក់ព័ន្ធណាមួយឡើយ[53]។

៤២. នៅថ្ងៃទី០៥ ខែឧសភា និងថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៦ អ្នកវិភាគដដែលរបស់ ក.ស.ច.ស បានទាក់ទងបុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីបញ្ជាក់ថាតើមជ្ឈមណ្ឌលឯកសារកម្ពុជា មានឯកសារពាក់ព័ន្ធនឹងកិច្ចស៊ើបសួរសំណុំរឿង តា ម៉ុក ដែរឬអត់។ បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា បានជូនដំណឹងអ្នកវិភាគរបស់ ក.ស.ច.ស ថា មជ្ឈមណ្ឌលឯកសារកម្ពុជា មិនដែលបានទាក់ទងតុលាការយោធា ហើយមិនមានឯកសារទាក់ទងនឹងកិច្ចស៊ើបសួរសំណុំរឿង តា ម៉ុក ទេ។ មជ្ឈមណ្ឌលឯកសារកម្ពុជា បានផ្តល់សំណៅឯកសារទាក់ទងនឹង តា ម៉ុក ជូនទៅបែនសុន សម័យ ប៉ុន្តែ ខ្លួនមិនបានរក្សាកំណត់ហេតុនៃឯកសារដែលបានថតចម្លងឡើយ ហើយមិនមានកម្រងឯកសារពិសេសរួចជាស្រេចទាក់ទងនឹង តា

---

[52] *សូមមើល* ខាងលើ កថាខណ្ឌ ២៣។

[53] សំណុំរឿង០០៤ ឯកសារ D219/818 *កំណត់ហេតុនៃកិច្ចស៊ើបសួរ* ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១៦ ទំព័រ ១។

ម៉ុក ឬបុគ្គលណាផ្សេងទៀតទេ។ បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា បានជូនដំណឹងអ្នកវិភាគរបស់ ក.ស.ច.ស ថា ឯកសារខ្លះក្នុងចំណោមឯកសារដដែលដែលបានប្រគល់ជូនបែន សុន សម័យ ធ្លាប់បានផ្ដល់ជូន ក.ស.ច.ស និងការិយាល័យសហព្រះរាជអាជ្ញារួចហើយ[54]។

៤៣. ជាផ្នែកមួយនៃកិច្ចស៊ើបសួរ បុគ្គលិករបស់ ក.ស.ច.ស បានត្រួតពិនិត្យឯកសារនៅក្នុងសំណុំរឿងផ្សេងទៀត ដើម្បីស្វែងរកឯកសារដែលពាក់ព័ន្ធនឹងសំណុំរឿង ០០៤ ដើម្បីដាក់ចូលក្នុងសំណុំរឿង ០០៤ ចំពោះឯកសារពាក់ព័ន្ធ។ ឯកសារទាំងនេះរាប់បញ្ចូលទាំងឯកសារទទួលបានពីមជ្ឈមណ្ឌលឯកសារកម្ពុជា ទាក់ទងនឹង តា ម៉ុក ដរាបណាឯកសារទាំងនោះពាក់ព័ន្ធនឹងសំណុំរឿង ០០៤។

៤៤. ប៉ុន្តែ ខ្ញុំជឿជាក់ថា ការស៊ើបសួរសមហេតុផលទាំងអស់ត្រូវបានធ្វើឡើងរួចហើយដើម្បីទទួលបានឯកសារពីមជ្ឈមណ្ឌលឯកសារកម្ពុជា ទាក់ទងនឹងកិច្ចស៊ើបសួរសំណុំរឿង តា ម៉ុក ហើយមិនចាំបាច់បំពេញកិច្ចស៊ើបសួរថែមទៀតដើម្បីឆ្លើយតបនឹងសំណើទី ១១ ឡើយ។

**តាមសំអាងហេតុខាងលើ ខ្ញុំ ៖**

៤៥. **ជូនដំណឹង** មេធាវីការពារក្ដី ថា ខ្ញុំយល់ឃើញថា បញ្ហាដែលបានស្នើនៅក្នុងសំណើទី ១ ទី៨ និង ១១ ត្រូវបានស៊ើបអង្កេតគ្រប់គ្រាន់រួចហើយ។

ភ្នំពេញ ថ្ងៃទី២៧ ខែ តុលា ឆ្នាំ ២០១៦

**ចៅក្រម Michael Bohlander**
**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**
**International Co- Investigating Judge**
**Co-juge d'instruction International**

---

[54]ដូចជើងទំព័រខាងលើ ទំព័រ ១-២។